# ផលប្រយោជន៍នៃសម្ព័ន្ធភាពគណបក្សនយោបាយ  នៅក្នុងការបោះឆ្នោត

នាពេលថ្មីៗចុងក្រោយនេះ  មានការសង្កេតឃើញការវិវត្តន៍ថ្មីៗគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងការត្រៀមរៀបចំរបស់គណបក្សនយោបាយផ្សេងៗនៅកម្ពុជា សម្រាប់ការបោះឆ្នោតទាំងកម្រិតមូលដ្ឋាន និងកម្រិតសភាតំណាងរាស្ត្រនៅអាណត្តិខាងមុខ។ ការសង្កេតឃើញមានបាតុភូតថ្មីមួយ ដែលគណបក្សនយោបាយមួយចំនួននៅកម្ពុជាទាំងនោះកំពុងចាប់ផ្តើមរកដៃគូចងសម្ព័ន្ធមុនដំណើរការបោះឆ្នោត។ ជារឿយៗកន្លងមក ការចងសម្ព័ន្ធច្រើនធ្វើឡើងនៅក្រោយពេលចេញលទ្ធផលបោះឆ្នោត ហើយការសម្រេចចិត្តនៅពេលទាំងឡាយនោះបានបង្កើតជាបទពិសោធន៍ជូរចត់ និងបរាជ័យ។

ការស្វះស្វែងរកការចងសម្ព័ន្ធនៅមុនការបោះឆ្នោតដូច្នេះ  អាចជាប្រការចំណេញក្នុងការគណនាអាសនៈចេញពីលទ្ធផលបោះឆ្នោត ដូចដែលមានការសង្កេតឃើញថា នៅដំណាក់កាលនេះ គណបក្សនយោបាយនីមួយៗកំពុងតែព្យាយាមស្វែងរកជម្រើសជាយុទ្ធសាស្ត្ររៀងៗខ្លួន តាមរយៈការចងសម្ព័ន្ធភាព។

យ៉ាងណាក៏ដោយ  ការចងសម្ព័ន្ធភាពរវាងគណបក្សនយោបាយនៅកម្ពុជាត្រូវបានគេមើលឃើញថា  នៅមានលក្ខណៈផុយស្រួយ  បើសិនមានតែការគិតអំពីផលប្រយោជន៍តែគណបក្សនយោបាយរៀងៗខ្លួន  ពោលគឺដើម្បីតួនាទីមុខតំណែងក្នុងសភា ឬនិងក្នុងរដ្ឋាភិបាលក្តី ជាជាងឧត្តមគតិ និងយុទ្ធសាស្ត្ររួមនោះ។

គួររំលឹកផងដែរថា បន្ទាប់ពីការអនុម័តយករូបមន្តសំឡេង ៥០%+១ សម្រាប់ការអនុម័តនៅក្នុងរដ្ឋសភា ពិសេសសម្រាប់ការបង្កើតរាជរដ្ឋាភិបាលកាលពីថ្ងៃទី២ ខែមីនា ឆ្នាំ២០០៦ មានការផ្លាស់ប្តូរមួយចំនួនគួរឱ្យកត់សម្គាល់ ក្នុងនោះសម្ព័ន្ធភាពរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច  នៅក្នុងរាជរដ្ឋាភិបាលចម្រុះអាណត្តិទី៣  ហាក់មានភាពរង្គោះរង្គើខ្លះៗជាលើកទី២ [លើកទី១ គឺការប្រេះឆានៅឆ្នាំ១៩៩៧តាមរយៈការប្រយុទ្ធគ្នា] បើទោះបីមានកិច្ចព្រមព្រៀងជាមួយគ្នាក៏ដោយ ដោយមានការដកតំណែងសំខាន់ៗ ដូចជារដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាល។ ដោយឡែក ចំពោះការវិវត្តន៍ចុងក្រោយមិនច្បាស់លាស់មួយ  ដែលមន្ត្រីគណបក្សហ៊្វុនស៊ិនប៉ិចបានលើកអំពីលទ្ធភាពក្នុងការចងសម្ព័ន្ធភាពជាមួយនឹងគណបក្សសមរង្ស៊ី ក្នុងបំណងបង្កើតជា "សម្ព័ន្ធភាពអ្នកជាតិនិយម" [ជាសម្ព័ន្ធភាពលើកទី៣ បន្ទាប់ពីការបែកបាក់ចេញពី "សម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ" កាលពីឆ្នាំ២០០៤]។ មួយផ្នែកផ្សេងទៀត គឺមានការចងជាសម្ព័ន្ធភាពរវាងគណបក្សតូចៗចំនួន៤ជា "សម្ព័ន្ធភាពសង្គមជាតិនិយម" ដែលដឹកនាំដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មកោ ក្នុងគោលដៅបង្កើតជាសម្ព័ន្ធគណបក្សនយោបាយមួយ ដើម្បីចូលរួមប្រកួតប្រជែង នៅក្នុងការបោះឆ្នោតនាពេលខាងមុខនេះ ។

ប្រព័ន្ធបោះឆ្នោតនៅកម្ពុជាបច្ចុប្បន្នមិនលើកទឹកចិត្តឱ្យមានគណបក្សនយោបាយច្រើន  មានលទ្ធភាពទទួលបានអាសនៈសភាឡើយ។ គណបក្សនយោបាយដែលទទួលបានឬសង្ឃឹមការគាំទ្រសំឡេងឆ្នោតតិចតួច មិនមានឱកាសទទួលបានអាសនៈពីរូបមន្តមធ្យមភាគខ្ពស់បំផុតទេ។ ជាក់ស្តែង ចំពោះលទ្ធផលបោះឆ្នោតតំណាងរាស្ត្រឆ្នាំ១៩៩៨ និង២០០៣ និងបោះឆ្នោតឃុំ-សង្កាត់២០០២ សំឡេងឆ្នោតដែលគណបក្សផ្សេងៗទទួលបានក្រៅពីគណបក្សមានអាសនៈសភាទាំង៣

គឺមានប្រហែលអ្នកបោះឆ្នោតឱ្យច្រើនជាង១០% (គឺច្រើនជាងកន្លះលាននាក់) ប៉ុន្តែពួកគេពុំអាចទទួលអាសនៈសភាបានទេ។ បើមើលគណបក្សឈ្នះសំឡេងឆ្នោតច្រើន ដូចជាគណបក្សប្រជាជនកម្ពុជា គណបក្សនេះបានសំឡេងឆ្នោតតែប្រហែល៤៧%នៃអ្នកបោះឆ្នោតទាំងអស់នៅឆ្នាំ២០០៣ ប៉ុន្តែនៅពេលគណនាអាសនៈ បានទទួលអាសនៈរហូតដល់ ៥៩% (៧៣អាសនៈ) ហើយដូចគ្នាដែរ គណបក្សសមរង្ស៊ីដែលទទួលបានសំឡេងឆ្នោតច្រើនជាងគណបក្សហ៊្វុនស៊ិនប៉ិចនៅក្នុងការបោះឆ្នោតឆ្នាំ២០០៣ ប៉ុន្តែតាមការគណនារូបមន្តនេះធ្វើឱ្យគណបក្សហ៊្វុនស៊ិនប៉ិចទទួលបានអាសនៈច្រើនជាងគណបក្សសមរង្ស៊ីទៅវិញ។ ឧទាហរណ៍ជាក់ស្តែងមួយផងដែរនៅក្នុងការលទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ ២០០២ នៅសង្កាត់ទួលសង្កែ រាជធានីភ្នំពេញ បង្ហាញថា គណបក្សហ៊្វុនស៊ិនប៉ិចទទួលបានសំឡេងឆ្នោតចំនួនជាង១៥% ប៉ុន្តែការគណនាអាសនៈវិញ គណបក្សនេះទទួលបានតែចំនួន៩%ប៉ុណ្ណោះ។ ទោះយ៉ាងណា ផ្តើមចេញពីមេរៀននេះគេគ្មានផ្លាស់ប្តូរប្រព័ន្ធបោះឆ្នោត រួមទាំងរូបមន្តគណនាអាសនៈឡើយ ដូចជារូបមន្តគណនាអាសនៈនៅឆ្នាំ១៩៩៣ -រូបមន្តសំណល់ធំ- ដែលអាចផ្តល់សំណល់ទៅឱ្យគណបក្សឈ្នះសំឡេងឆ្នោតបន្ទាប់។ ក្នុងករណីមិនមានការកែលម្អប្រព័ន្ធបោះឆ្នោត និងរូបមន្តគណនាអាសនៈនោះ លទ្ធភាពមួយទៀតគឺគណបក្សធ្លាប់បានសន្លឹកឆ្នោតតិចតួច និងមានធនធានកំណត់គួរចងគ្នាជាសម្ព័ន្ធ ដើម្បីប្រមូលផ្តុំសន្លឹកឆ្នោត នៅក្នុងគណបក្សនយោបាយមួយ។

ជាការពិត មានបញ្ហាក្នុងការចងសម្ព័ន្ធភាពរបស់គណបក្សនយោបាយផ្សេងៗនៅកម្ពុជា នោះគឺជំងឺ និងវប្បធម៌មួយនៃការមិនជឿទុកចិត្តគ្នា។ ជាក់ស្តែង នៅដំណាក់កាលដំបូងនេះមានទំនាស់ជាពាក្យសម្តីរវាងមេដឹកនាំគណបក្សនយោបាយ ដោយមានការប្រើពាក្យថា "គណបក្សអាបមានតែក្បាល គ្មានដងខ្លួន និងអវៈយវៈ" "សម្ព័ន្ធភាពទឹកកកដែលងាយនឹងរលាយទៅវិញ" "គណបក្ស...ចង់បានតែ អំណាច និងស្រី... គ្មានមនសិការទេ"... ។ល។

គណបក្សនយោបាយនានាគួរខិតខំរិះរកមធ្យោបាយ និងយុទ្ធសាស្ត្រថែមទៀត ក្នុងការចងសម្ព័ន្ធជាមួយគ្នានៅពេលមានឧត្តមគតិ និងទស្សនៈប្រហាក់ប្រហែលគ្នា សម្រាប់ចូលរួមប្រកួតក្នុងការបោះឆ្នោតឃុំ-សង្កាត់២០០២ និងបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ២០០៨។ ការចងសម្ព័ន្ធមិនមែនចាំបាច់ត្រូវមានរចនាសម្ព័ន្ធជាអង្គការចាត់តាំងនឹងថ្កល់នោះទេ ឬក៏មិនចាំបាច់រំលាយគណបក្សជាសមាជិកដែរ ប៉ុន្តែគេអាចចងសម្ព័ន្ធគ្នាក្នុងកម្រិតព្រមព្រៀងយុទ្ធសាស្ត្ររួមក៏បាន ឧទាហរណ៍ដូចជាការចែកមណ្ឌលឈរឈ្មោះសម្រាប់គណបក្សមានសក្តានុពល ប្រមូលផ្តុំធនធានឃោសនាបោះឆ្នោត ។ល។